PHL ConnectED
DIAL 2-1-1



# ការភ្ជាប់គ្រួសារសិស្សថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី 12 ក្នុងក្រុងហ្វីឡាឌែលហ្វៀ ជាមួយនឹងបណ្តាញអ៊ិនថឺណិត ដោយឥតគិតថ្លៃ សម្រាប់ការសិក្សាឌីជីថល

*តើគ្រួសារអ្នកត្រូវការប្រើអ៊ិនថឺណិតដែលមិនមានភាពរអាក់រអួលដែរឬទេ? តើអ្នកអាចប្រើប្រាស់អ៊ិនថឺណិតតែតាមរយៈទូរស័ព្ទចល័តមែនទេ?*

*PHLConnectED អាចជួយគ្រួសារអ្នក ឲ្យមានអ៊ិនថឺណិតប្រើ បើសិនជាត្រូវការ ដើម្បីឲ្យកូនអ្នកចាប់ពីថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី 12 អាចភ្ជាប់អ៊ិនថឺណិត សម្រាប់ការសិក្សា ។*

## តើអ្វីជា PHLConnectED?

PHLConnectED គឺជាគម្រោងដែលផ្តួចផ្តើមដោយសាលាក្រុង សម្រាប់ជួយដល់គ្រួសារសិស្សពីថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី 12 អាចមានអ៊ិនថឺណិតប្រើប្រាស់ដោយមិនរអាក់រអួល មិនអស់ប្រាក់ និងគួរឲ្យជឿជាក់បាន ។

ពីពេលនេះ រហូតដល់រដូវក្តៅ ឆ្នាំ 2022 សិស្ស និងគ្រួសាររបស់សិស្ស ដែលមានសិទ្ធិទទួលបានជំនួយពីកម្មវិធីនេះ នឹងអាចចុះឈ្មោះដើម្បីប្រើប្រាស់អ៊ិនថឺណិតចាំបាច់ (Internet Essentials) របស់ក្រុមហ៊ុន Comcast ឬយោងតាមតម្រូវការ គឺអាចចុះឈ្មោះប្រើប្រាស់ហតស្ប៉តរបស់ក្រុមហ៊ុន T-Mobile MiFi ដោយឥតគិតថ្លៃ ។

## នរណាអាចទទួលបានអ៊ិនថឺណិតប្រើតាមរយៈគម្រោង PHLConnectED?

គ្រួសារសិស្សថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី 12 អាចទទួលបានសេវាកម្មនេះ ប្រសិនបើពួកគេ ៖

- មិនមានអ៊ិនថឺណិតប្រើប្រាស់ ឬ
- ប្រើអ៊ិនថឺណិតតែតាមរយៈទូរស័ព្ទដៃ ឬ
- គ្មានផ្ទះស្នាក់នៅ ឬមិនមានសុវត្ថិភាពលំនៅឋាន ឬ
- រស់នៅតំបន់ដែលគ្មានអ៊ិនថឺណិតប្រើប្រាស់ តែកូនៗត្រូវរៀនតាមអនឡាញ ។

បើគ្រួសារសិស្សមានអ៊ីនថឺណិតសម្រាប់ប្រើប្រាស់ក្នុងផ្ទះរួចហើយ ក៏ពួកគេអាចមានសិទ្ធិទទួលបានជំនួយនេះដែរ ប្រសិនបើពួកគេ ៖

- បានទទួលទទួលជំនួយអត្ថប្រយោជន៍សាធារណៈ ដោយគិតលើកម្រិតប្រាក់ចំណូលក្នុងគ្រួសារ ដូចជាជំនួយពីកម្មវិធី Medicaid ឬ
- កូនរបស់ខ្លួនស្ថិតក្នុងស្ថានភាពជាអ្នកត្រូវការពង្រឹងសមត្ថភាពភាសាអង់គ្លេសបន្ថែម ឬ
- មានកូនដែលជាអ្នកកំពុងទទួលសេវាកម្មអប់រំពិសេស ។

## របៀបទំនាក់ទំនង

បើអ្នកចង់ដឹងបន្ថែមអំពីគម្រោង PHLConnectED និងចង់ដឹងថាតើអ្នកមានសិទ្ធិទទួលបានសេវាកម្មនេះដែរឬទេ សូមចុចទូរស័ព្ទមកលេខ 2-1-1 ។ សម្រាប់សេវាកម្មបកប្រែភាសា សូមចុចលេខ 8 ។

លេខទូរស័ព្ទទាន់ហេតុការណ៍ មានបម្រើសេវាកម្ម 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ ហើយមានបម្រើសេវាកម្មជាភាសាផ្សេងៗចំនួន 150 ភាសា ។

City of Philadelphia